**សុន្ទរកថា**
**ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
**រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**
**ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨របស់**
**ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**
**ថ្ងៃទី២៨ ខែកុម្ភៈ – ០២ ខែមីនា ឆ្នាំ២០១៨**

- សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- សូមគោរពគណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង/ស្ថាប័ន
- ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គសន្និបាតទាំងអស់ជាទីមេត្រី

ជាបឋម ខ្ញុំបាទសូមស្វាគមន៍នូវវត្តមាន និងការអញ្ជើញជាអធិបតីដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

តាងនាមអោយមន្ត្រីរាជការនៃក្រសួងការបរទេសទាំងមូល ខ្ញុំក៏សូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលជាថ្នាក់ដឹកនាំកំពូលប្រកបដោយទស្សនវិស័យវែងឆ្ងាយក្នុងវិស័យការទូត ដែលជានិច្ចកាល **សម្តេច** តែងតែចង្អុលបង្ហាញ និងផ្តល់នូវអនុសាសន៍ដ៏ឧត្តុង្គឧត្តម និងការយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះការងារក្នុងវិស័យការបរទេស ក៏ដូចជា មន្ត្រីការទូត មន្ត្រីរាជការ និងបុគ្គលិកក្រសួងការបរទេសទាំងមូល ។

ខ្ញុំក៏សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ដែលបានអញ្ជើញចូលរួមក្នុងសន្និបាតនេះ ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

នេះគឺជាសន្និបាតប្រចាំឆ្នាំ ដែលយើងខិតខំរៀបចំឡើងដើម្បីអោយក្លាយជាប្រពៃណី និងវប្បធម៌របស់ក្រសួង សំដៅលើកកំពស់ប្រសិទ្ធភាពការងារ ដណ្តើមជោគជ័យលើសមរភូមិការទូត ការពារផលប្រយោជន៍ជាតិ និងលើកកំពស់កិត្តនាម កិត្តិយសជាតិនៅក្នុងពិភពលោក។ ខ្ញុំមានសេចក្តីសោមនស្ស

រីករាយក្រៃលែងដែលក្រសួងបានបញ្ចប់នូវការប្រជុំរយៈពេល៣ថ្ងៃ ដែលជា ៣ថ្ងៃ ពេញដោយខ្លឹមសារនៃការពិគ្រោះពិភាក្សាគ្នាដោយត្រង់ៗ ផ្លាស់ប្តូរយោបល់ មេរៀនបទពិសោធន៍ទាក់ទងនឹងការងាររបស់ក្រសួងកន្លងទៅ។

សន្និបាតឆ្នាំនេះខុសពីឆ្នាំមុនត្រង់២ចំណុច គឺទី ១ យើងបានផ្តល់ពេលវេលាយ៉ាងច្រើនសម្រាប់កិច្ចប្រជុំចង្អៀតដែលមានរយៈពេល១ថ្ងៃកន្លះ ដោយផ្តោតសំខាន់លើប្រធានបទ៣គឺ ទី១ ការវាយតម្លៃស្ថានភាពនយោបាយ និងយុទ្ធសាស្រ្តពង្រឹងទំនាក់ទំនងទ្វេ/ពហុភាគី ទី២ បញ្ហាពលករ និងសហគមន៍ខ្មែរនៅបរទេស និងទី៣ បញ្ហាប្រឈមរបស់ស្ថានតំណាងកម្ពុជានៅក្រៅប្រទេស។ ទី២ គឺការពិភាក្សាលើខ្លឹមសារនៃសុន្ទរកថារបស់ខ្ញុំនៅក្នុងឱកាសបើកសន្និបាត សំដៅដាក់ចេញនូវ "ឯកសារគោលនយោបាយការទូត"ដែលគូសបញ្ជាក់ពីទិសដៅការងារអាទិភាព និងយុទ្ធសាស្រ្តការទូតប្រចាំឆ្នាំរបស់កម្ពុជា ដើម្បីពង្រីកការផ្សព្វផ្សាយពីទស្សនៈរបស់កម្ពុជាក្នុងមជ្ឈដ្ឋានការទូតផង និងដើម្បីឲ្យអ្នកការទូតយើងទូទាំងពិភពលោកប្រើប្រាស់ជាត្រីវិស័យក្នុងការអនុវត្តការងារផងដែរ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ក្នុងថ្ងៃដំបូង អង្គសន្និបាតបានស្តាប់បទឧទ្ទេសនាមលើប្រធានបទទាក់ទងនឹងចលនាបដិវត្តពណ៌ និងវិធានការច្បាប់ដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា ដែលឧទ្ទេសនាមដោយឯកឧត្តមរដ្ឋលេខាធិការ ព្រុំ សុខា និងឯកឧត្តម កើត រិទ្ធ និងប្រធានបទស្តីពី យុទ្ធសាស្រ្តជម្រុញទីផ្សារនិងប្រព័ន្ធអនុគ្រោះពន្ធមកលើកម្ពុជា ដោយលោកជំទាវ តឹករ៉េត កំរង។

"នៅពេលដែលមានសន្តិភាព យើងមិនដែលនឹកឃើញដល់សង្គ្រាមទេ។ ប៉ុន្តែពេលមានសង្គ្រាមទើបយើងនឹកឃើញដល់សន្តិភាព"។ តាមរយៈបទបង្ហាញរបស់វាគ្មិនយើង យើងបានយល់ដឹងកាន់តែច្បាស់អំពីផែនការដ៏អាក្រក់ដែលមានការរៀបចំយ៉ាងហ្មត់ចត់ និងយុទ្ធសាស្រ្តរយៈពេលវែងក្រោមការបង្ហាត់បង្រៀនបច្ចេកទេស និងគាំទ្រហិរញ្ញវត្ថុពីបរទេស របស់ក្រុមអ្នកលក់ជាតិបម្រើឲ្យមហិច្ឆតាបរទេសដើម្បីតែអំណាចរបស់ខ្លួនឯង ហ៊ានលះបង់ផលប្រយោជន៍ជាតិ និងសុខសន្តិភាពរបស់ប្រជាជាតិទាំងមូលដោយគ្មានមនសិការទទួលខុសត្រូវចំពោះជោគវាសនារួមនៃប្រទេសជាតិមួយដែលធ្លាប់ស្គាល់តែសង្គ្រាមរ៉ុាំរ៉ៃ។

នេះគឺជាតថភាពជាក់ស្តែងនៃគ្រោះថ្នាក់នៃបដិវត្តន៍ពណ៌ ដែលជំរុញ "ប្រជាធិបតេយ្យក្រៅច្បាប់" តាមរយៈការគាំទ្រឲ្យមានការប្រឆាំងនឹងរដ្ឋអំណាច ក្រោមស្លាក "អហិង្សា" ហើយចុងក្រោយគឺផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ដោយហិង្សាប្រជាជន និងបង្កឲ្យមានសង្គ្រាមស៊ីវិលគ្មានច្រកចេញ នៅបណ្តាប្រទេសជាច្រើន។ ការបង្កើត "ចលនាសង្គ្រោះជាតិ" នាពេលថ្មីៗនេះ មិនបានយកស្លាក "អហិង្សា" មកប្រើប្រាស់ទៀតទេ គឺគេបានផ្តោតលើការញុះញង់យ៉ាងច្បាស់ក្រឡែតឲ្យប្រជាជន និងកងទ័ពបះបោរប្រឆាំងនឹងរដ្ឋអំណាច ដែលនេះគឺជាចលនាខុសច្បាប់មិនអាចប្រកែកបាន។

ក្នុងបទបង្ហាញពីក្រសួងពាណិជ្ជកម្ម យើងបានយល់ពីបច្ចុប្បន្នភាពនៃសកម្មភាពផ្លាស់ប្តូរពាណិជ្ជកម្មជាមួយគ្រប់ប្រទេសដៃគូក្នុងពិភពលោក។ ផ្អែកលើសន្តិភាព និងស្ថិរភាព យើងបានអភិវឌ្ឍដល់កម្រិតមួយដែលអាចឈានបណ្តើរៗទៅរកការចាកចេញពីឋានៈជា "ប្រទេសដែលមានការអភិវឌ្ឍតិចតួច" (LDCs)។ យើងបានដឹងយ៉ាងច្បាស់ថា ក្របខណ្ឌអនុគ្រោះពន្ធដូចជា "អ្វីៗទាំងអស់លើកលែងតែអាវុធ" ឬ EBA មិននៅស្ថិតស្ថេររហូតនោះទេ ជាពិសេសនៅពេលដែលកម្ពុជានឹងចាកចេញពីឋានៈជា LDCs ក្នុងពេលឆាប់ៗខាងមុខនេះ ដែលប្រការនេះទាមទារឲ្យកម្ពុជាត្រៀមខ្លួនជាមុន និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងចង្វាក់តម្លៃ និងចង្វាក់ផ្គត់ផ្គង់សកល។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ទាក់ទងនឹងការងារកំណែទំរង់ អង្គសន្និបាតបានឯកភាពទាំងស្រុង ក្នុងការបន្តដំណើរការកំណែទំរង់របស់ក្រសួង ដើម្បីឧត្តមប្រយោជន៍ជាតិ តាមរយៈការកែលំអលក្ខខណ្ឌនិងបរិស្ថានការងារ ការគិតគូរអំពីជីវភាពមន្ត្រីនិងបុគ្គលិក និងការពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងក្រមសីលធម៌របស់អ្នកការទូត។

កាលពីសប្តាហ៍មុន យើងទើបតែបានសម្ពោធដាក់ឲ្យប្រើប្រាស់ និងដំណើរការនូវវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ដែលជាសមិទ្ធផលដ៏ធំធេង និងជោគជ័យដ៏ថ្មីស្រឡាងសម្រាប់មន្ត្រីក្រសួងគ្រប់រូប និងមានអត្ថន័យជាប្រវត្តិសាស្ត្រ ក្នុងបរិបទដែលកម្ពុជាបានបង្កើតជាលើកដំបូងនូវវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ចំណុះអោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ សម្រាប់មន្ត្រីការទូតយើងទាំងអស់គ្នា ការបង្កើត និងចាប់ផ្តើមដំណើរការនៃវិទ្យាស្ថាននេះ វាប្រៀបបានដូចជា "**សុបិន្តក្លាយជាការពិត**" ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ក្នុងអង្គប្រជុំចង្អៀត យើងបានពិភាក្សាពីលទ្ធភាពនៃការដាក់ចេញនូវ "ឯកសារគោលនយោបាយការទូត" ដោយផ្អែកលើសុន្ទរកថាបើកសន្និបាតរបស់ខ្ញុំ។ យើងបានប្រមែប្រមូលធាតុចូលបន្ថែមឲ្យបានគ្រប់ជ្រុងជ្រោយពីគ្រប់បណ្តាសេនាធិការទាំងអស់របស់ក្រសួងទាំងនៅក្នុង និងក្រៅប្រទេស។ ឯកសារនេះនឹងផ្សព្វផ្សាយជាសាធារណៈនៅពេលដែលមានគោលការណ៍ឯកភាពពី **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

ក្នុងឯកសារនេះ យើងបានកំណត់នូវចរន្តធំៗចំនួន ៣ ក្នុងចំណោមចរន្តសំខាន់ៗជាច្រើនផ្សេងទៀត ដែលបានកើតឡើងនៅឆ្នាំ ២០១៧ ហើយដែលមានសារៈសំខាន់សម្រាប់ពិភពលោក តំបន់ និងសម្រាប់កម្ពុជា។ ចរន្តធំទាំង៣ ដែលបានវិវត្តក្នុងបរិបទនៃពិភពលោកពហុប៉ូលនោះគឺបត់នយោបាយថ្មីរបស់រដ្ឋការលោកប្រធានាធិបតី Trump ជាមួយនឹងទិសស្លោក "ផលប្រយោជន៍អាមេរិកមុនគេ (America First)" និងការចាកចេញរបស់អង់គ្លេសពី EU (Brexit) និងការរៀបចំផ្ទៃក្នុង EU ឡើងវិញ និងការបន្តងើបឡើងយ៉ាងប្រត្យក្សនៃប្រទេសចិន។

ផ្អែកលើចរន្តទាំងនេះ អង្គប្រជុំបានដាក់ចេញនូវការងារអាទិភាពចំនួន ៥គឺ៖

- ទីមួយ គឺការការពារផលប្រយោជន៍ជាតិ ជាពិសេសការពារឯករាជ្យ និងអធិបតេយ្យ ។
- ទី២ គឺការអនុវត្តនូវនយោបាយការបរទេសប្រកបដោយភាពបត់បែន រៀងវៃ តបទៅនឹងសម្ពាធភូមិសាស្រ្តនយោបាយ និងការប្រកួតប្រជែងដ៏តានតឹងរបស់មហាអំណាចនានា ដោយប្រកាន់ខ្ជាប់នូវគោលការណ៍អព្យាក្រិត្យ និងមិនចូលបក្សសម្ព័ន្ធ ដូចមានចែងក្នុងមាត្រា៥៣ នៃរដ្ឋធមនុញ្ញ ។
- ទី៣ គឺអនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌ ដើម្បីពង្រឹងសេដ្ឋកិច្ចជាតិយើង ។
- ទី ៤ គឺការចូលរួមអោយកាន់តែសកម្មថែមទៀតដល់បុព្វហេតុ សន្តិភាព ស្ថិរភាព និងការប្រយុទ្ធនឹងការប្រឈមនានានៃពិភពលោក។
- ទី៥ របស់យើងគឺ ការបន្តការដ្ឋានកំណែទំរង់ស្ថាប័ននៅក្នុងក្រសួង ដើម្បីរៀបចំអង្គអ្នកការទូតប្រកបដោយវិជ្ជាជីវៈ ស្នេហាជាតិ សកម្ម និងមានសមត្ថភាព ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី!

បន្ថែមលើការពិភាក្សាអំពី "ឯកសារគោលនយោបាយការទូត" អង្គប្រជុំក៏បានពិភាក្សាអំពីបញ្ហាប្រឈមនានា និងកិច្ចខិតខំប្រឹងប្រែងរបស់ស្ថានតំណាងក្នុងការដោះស្រាយបញ្ហាពលករក្រៅប្រទេសរបស់កម្ពុជា និងការផ្តល់សេវានានាដល់សហគមន៍ខ្មែរនៅបរទេស។

បញ្ហាពលករក្រៅប្រទេស ជាពិសេសនៅប្រទេសថៃ គឺជាបញ្ហាប្រឈមដែលមានភាពប្រទាក់ក្រឡាចំរុះស្ថាប័ន និងទាមទារឲ្យមានដំណោះស្រាយជាប្រព័ន្ធតាំងពីដើមទី រហូតដល់ចុងទី ពោលគឺត្រូវមានប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ និងការអប់រំ បណ្តុះបណ្តាលអំពីសិទ្ធិជាមូលដ្ឋានរបស់ពលករ តាំងពីមុនពេលបញ្ជូនពលករចេញ។ អង្គប្រជុំបានពិចារណាក្នុងការរៀបចំជាឯកសារទស្សនាទានស្តីពីបញ្ហាពលកររបស់កម្ពុជា ដើម្បីឈានទៅរកការសិក្សាស្វែងរកដំណោះស្រាយជាប្រព័ន្ធចំរុះស្ថាប័នចំពោះបញ្ហាទាំងនេះ។

អង្គប្រជុំក៏បានលើកឡើងផងដែរអំពីបញ្ហាប្រឈមនិងកង្វះខាតនៃយន្តការគ្រប់គ្រង និងសេវាគាំពារពលករ ព្រមទាំងនិស្សិតខ្មែរឥស្លាមនៅតំបន់មជ្ឈិមបូព៌ា។

អង្គប្រជុំក៏បានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងបង្កើនសាមគ្គីភាព និងភាតរភាពជាមហាគ្រួសារខ្មែរដែលស្ថានតំណាងនៅក្រៅប្រទេសបាននិងកំពុងធ្វើ តាមរយៈយន្តការជាច្រើនដូចជា ការខិតខំចុះផ្ទាល់ទៅដល់មូលដ្ឋានដែលមានពលរដ្ឋខ្មែររស់នៅច្រើន ការបង្កើតបណ្តាញទំនាក់ទំនងជាមួយភោជនីយដ្ឋានខ្មែរ ការបង្កើនភាពងាយស្រួលក្នុងការទទួលបានសេវាសាធារណៈ ការសហការជាមួយក្រុមគ្រូពេទ្យនិងមេធាវីស្ម័គ្រចិត្ត ការប្រើប្រាស់មជ្ឈមណ្ឌលគាំពារពលករ ការជួយគាំទ្រទាន់ពេលវេលាដល់ពលករពេលមានគ្រោះថ្នាក់ការងារ ការរៀបចំវេទិកាសាធារណៈដើម្បីស្តាប់អំពីបញ្ហាប្រឈមនានារបស់ពលរដ្ឋខ្មែរ ការរៀបចំកម្មវិធីវប្បធម៌ និងសាសនារួមគ្នាជាមួយសហគមន៍ខ្មែរ ជាដើម។ល។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ក្រសួងការបរទេសមានតួនាទីសំខាន់ណាស់ក្នុងការដើរតួជាសេនាធិការរបស់រាជរដ្ឋាភិបាលតាមរយៈការប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ និងការព្យាយាមសម្រេចអោយបាននូវការរួមរស់ដោយសន្តិសហវិជ្ជមាន និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយគ្រប់ប្រទេសជាមិត្តលើសកលលោក។ យើងមានតួនាទីការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ និងការការពារភាពស្របច្បាប់របស់រាជរដ្ឋាភិបាលដែលប្រសូតចេញពីឆន្ទៈប្រជាជនកម្ពុជាយ៉ាងពិតប្រាកដ។ យើងមានកាតព្វកិច្ចក្នុងការចូលរួមការពារសន្តិភាព ស្ថិរភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ និងយកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ។

ដូចដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលជាអគ្គមគ្គុទេសក៍ក្នុងវិស័យការទូតតែងតែលើកឡើងថា "នយោបាយក្នុងស្រុក និងនយោបាយក្រៅប្រទេសគឺបម្រើអោយគ្នាទៅវិញទៅមក" ។ កិច្ចសហប្រតិបត្តិការក្រៅប្រទេសមិនអាចកាត់ផ្តាច់ចេញពីការវិវត្តនៃសភាពការណ៍ក្នុងស្រុក ហើយការអភិវឌ្ឍក្នុងប្រទេសក៏មិនអាចកាត់ផ្តាច់ពីទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក្នុងសហគមន៍អន្តរជាតិដូចគ្នា ។

ដូច្នេះ ក្នុងបរិការណ៍ឆ្នាំ ២០១៨ វិញ្ញាសារការទូតសម្រាប់ក្រសួងការបរទេសកាន់តែមានភាពស្មុគស្មាញ ប៉ុន្តែ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សាបាននូវឯករាជ្យ អធិបតេយ្យ ការបង្រួបបង្រួមជាតិ និងជាពិសេសសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ និងយកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ។ វិញ្ញាសារទាំងនេះ ទាមទារអោយក្រសួងការបរទេសទាំងមូល និងស្ថាប័នពាក់ព័ន្ធ បំពេញភារកិច្ចតាមមុខងាររបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងស្មារតីទទួលខុសត្រូវរួមគ្នាលើជោគវាសនាប្រទេសជាតិ ។

ចំពោះទិសដៅខាងមុខ ខ្ញុំសូមអំពាវនាវដល់មន្ត្រីក្រសួងការបរទេសគ្រប់ជាន់ថ្នាក់ សូមបន្តពង្រឹងសមត្ថភាពរបស់ខ្លួន ក៏ដូចជាសមត្ថភាពស្ថាប័ន ដើម្បីបង្កើនលទ្ធភាពក្នុងការប្រកួតប្រជែង ជម្រុញ និងការពារផលប្រយោជន៍ និងកិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ និងសូមបន្តគាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងការងារកំណែទម្រង់ ដើម្បីបុព្វហេតុរួមរបស់យើងទាំងអស់គ្នា ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ជាថ្មីម្តងទៀតខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រ និងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងបានគាំទ្រដល់កិច្ចប្រឹង

ប្រែងរបស់យើងខ្ញុំក្នុងការកែទំរង់នានា និងបានដឹកនាំវិស័យការទូតប្រកបដោយសុភវិនិច្ឆ័យ និងគតិបណ្ឌិតសំរាប់កម្ពុជាមួយឯករាជ្យ អធិបតេយ្យ សន្តិភាព អភិវឌ្ឍន៍ និងប្រកបដោយសេចក្តីថ្លៃថ្នូរ ។

ខ្ញុំក៏សូមអរគុណបណ្តាក្រសួង ស្ថាប័ន ស្ថានទូត ស្ថានបេសកកម្ម អង្គការអន្តរជាតិនានាដែលតែងផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់បេសកកម្មរបស់ក្រសួង ។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ទទួលបាននូវពុទ្ធិពរទាំងប្រាំប្រការ និងទទួលបាននូវជ័យ ជំនះគ្រប់ភារកិច្ច។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង** វីរជនការទូតកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាមានប្រសាសន៍សំណេះសំណាល និងពាំនាំនូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រីផ្ញើជូនមន្ត្រីក្រោមឱវាទក្រសួងការបរទេសទាំងអស់ ។ សូមគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ។

***សូមអរគុណ!***